01324728

E319/35/6

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 09 / 2016
ម៉ោង (Time/Heure) : 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម យ៉ា សុខន ជ. ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើការស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-1002 ក្នុងសវនាការជាអសាធារណៈ**

១. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើឱ្យសាក្សី 2-TCW-1002 ផ្តល់សក្ខីកម្មនៅក្នុងសវនាការជាអសាធារណៈ។ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីទៅលើសំណើនេះ។ សហព្រះរាជអាជ្ញាលើកឡើងថា សាក្សី 2-TCW-1002 គឺជាសាក្សីដ៏សំខាន់មួយ នៅក្នុងការស៊ើបអង្កេតដែលកំពុងធ្វើនាពេលបច្ចុប្បន្ននេះ ហើយគាត់មិនដែលបានផ្តល់ចម្លើយនៅក្នុងសំណុំរឿង ០០២ ទេ។ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសំណើសុំឱ្យស្តាប់សក្ខីកម្មសាក្សីរូបនេះនៅក្នុងសវនាការជាអសាធារណៈទេ។ មេធាវីការពារក្តី នួន ជា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានមតិយោបល់ទៅលើបញ្ហានេះទេ។ មេធាវីការពារក្តី ខៀវ សំផន កត់សម្គាល់ថា សវនាការនេះគួរតែមានតម្លាភាព ប៉ុន្តែមិនបានធ្វើការជំទាស់ជាក់លាក់ចំពោះការស្តាប់សក្ខីកម្មសាក្សី 2-TCW-1002 នៅក្នុងសវនាការជាអសាធារណៈទេ។

២. អង្គជំនុំជម្រះរំលឹកថា នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នៅក្នុងអនុស្សរណៈមួយស្តីអំពីការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២ (ឯកសារ

E319/35) ស.ច.ស.អ បានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា បន្ទាប់ពីការពិនិត្យលើភ័ស្តុតាងដែលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូនរួចមក គាត់នឹងស្នើសុំឱ្យប្រើប្រាស់សវនាការអសាធារណៈ និង វិធានការផ្សេងៗទៀតដែលចាំបាច់ក្រៅពីការប្រើប្រាស់រហស្សនាម សម្រាប់សាក្សីមួយចំនួនតូចដែល "សំខាន់ផ្ទាល់នៅក្នុងកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៣ ឬ ០០៤" "ដើម្បីធានាសុចរិតភាពនៃភ័ស្តុតាង" (ឯកសារ E319/35 កថាខណ្ឌ ៣.គ)។

៣. អង្គជំនុំជម្រះរំលឹកថា អនុលោមតាមមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធាន ៧៩(៦) នៃវិធានផ្ទៃក្នុង សវនាការត្រូវតែធ្វើឡើងជាសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានទទួលស្គាល់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង អនុលោមតាមច្បាប់អន្តរជាតិ សិទ្ធិទទួលបានសវនាការជាសាធារណៈមិនមានលក្ខណៈដាច់ខាតនោះឡើយ។ នៅក្នុងកាលៈទេសៈពិសេសដែលប្រយោជន៍យុត្តិធម៌តម្រូវ តុលាការអាចសម្រេចអនុវត្តកិច្ចដំណើរការនីតិវិធីជាអសាធារណៈ។ អង្គជំនុំជម្រះធ្លាប់បានសម្រេចថា ការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការអាចជា "មូលហេតុត្រឹមត្រូវ" សម្រាប់កិច្ចដំណើរការនីតិវិធីជាអសាធារណៈ (ឯកសារ E319/35/5 កថាខណ្ឌ ២-៣, ៥)។

៤. ផ្អែកលើសារណារបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះយល់ឃើញថា មានមូលហេតុត្រឹមត្រូវនៅក្នុងការរៀបចំកិច្ចដំណើរការនីតិវិធីសវនាការជាអសាធារណៈ ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មសាក្សី 2-TCW-1002 គួរប្រព្រឹត្តទៅនៅក្នុងសវនាការជាអសាធារណៈទាំងស្រុង អនុលោមតាមមាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធាន ៧៩(៦)(ខ) នៃវិធានផ្ទៃក្នុង។

៥. ដើម្បីធ្វើឱ្យសវនាការទាំងនេះមានលក្ខណៈជាសាធារណៈក្នុងកម្រិតអតិបរមានោះ អង្គជំនុំជម្រះនឹងកោសលុបប្រតិចារឹកសវនាការអសាធារណៈ ដោយពិគ្រោះយោបល់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សូមមើល ឯកសារ E319/35/2 កថាខណ្ឌ ៤) ដើម្បីអាចឱ្យប្រតិចារឹកសវនាការទាំងនេះ ដាក់ផ្សាយជាសាធារណៈបាន។ លើសពីនេះទៀត ផ្នែកសម្ងាត់នៃប្រតិចារឹកទាំងនេះ អាចត្រូវបានចាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនៅពេលក្រោយទៀត ប្រសិនបើហេតុផលដែលផ្តល់យុត្តិកម្មចំពោះការកោសលុបប្រតិចារឹកទាំងនោះ លែងមានភាពចាំបាច់ហើយនោះ។